ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ សុក្រ ១១ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការដាក់ឲ្យដំណើរការ "គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម"

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យម មេត្តាជ្រាបថា ក្រោមគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា ***"គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម"*** ត្រូវបានបង្កើតឡើង និងដាក់ឲ្យដំណើរការជាផ្លូវការចាប់ពីពេលនេះតទៅ ។

***"គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាស ធុនតូច និងមធ្យម"*** មានគោលបំណងផ្តល់ឥណទាន មានការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ដូចជា ផ្នែកកម្មន្តសាល និងសិប្បកម្ម សម្រាប់ជំនួសឲ្យការនាំចូលបម្រើសេចក្តីត្រូវការក្នុងស្រុក ឬបម្រើជាធាតុចូលនៅក្នុងការផលិតរបស់ក្រុមហ៊ុនធំៗ ជាដើម ។ មូលនិធិក្រោមគម្រោងសហហិរញ្ញប្បទាននេះ មានទំហំទឹកប្រាក់ ១០០ លានដុល្លារអាមេរិក ដែលជាការផ្តល់សហហិរញ្ញប្បទានបដិភាគស្មើគ្នារវាងធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា (ធ.ស.ក) និងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ (គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម) ។ គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមនៃគម្រោងសហហិរញ្ញប្បទាននេះ មានចំនួន ៣៣ ក្នុងនោះ ធនាគារពាណិជ្ជចំនួន ២៣, ធនាគារឯកទេសចំនួន ២, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥, និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ។

សហគ្រាសធុនតូច និងមធ្យម ដែលមានតម្រូវការឥណទាន អាចដាក់ពាក្យស្នើសុំឥណទាន ក្រោមគម្រោងសហហិរញ្ញប្បទាននេះ នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមណាមួយ ដោយគោរពតាមលក្ខខណ្ឌរបស់គម្រោងសហហិរញ្ញប្បទាន និងលក្ខខណ្ឌផ្តល់ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ចូលរួមនីមួយៗ ។ ដើម្បីអាចទទួលបានឥណទានក្រោមគម្រោងសហហិរញ្ញប្បទាននេះ, សហគ្រាសធុនតូច និងមធ្យម ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមលក្ខណៈវិនិច្ឆ័យខាងក្រោម÷

១. ជាសហគ្រាសដែលបានចុះបញ្ជីផ្លូវការ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់និយមន័យដូចខាងក្រោម÷

- សហគ្រាសធុនតូច សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី ២៥០.០០០.០០០ (ពីររយហាសិបលាន) រៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ពី ១០នាក់ ទៅ ៥០នាក់ ។
- សហគ្រាសធុនមធ្យម សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៧០០.០០០.០០០ (ប្រាំពីររយលាន) រៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ស្របតាមច្បាប់ និងបទ- ប្បញ្ញត្តិស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ពី ៥១នាក់ ទៅ ១០០នាក់ ។

២. ជាសហគ្រាសដែលធ្វើប្រតិបត្តិការអាជីវកម្មក្នុងវិស័យអាទិភាព (លើកលែងវិស័យដែលពាក់ព័ន្ធដល់វិស័យសន្តិសុខសង្គម សុខភាព បរិស្ថាន) ដូចខាងក្រោម÷
- ផលិត និងកែច្នៃម្ហូបអាហារ,
- កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក កែច្នៃកាកសំណល់ និងផលិត ទំនិញសម្រាប់វិស័យទេសចរណ៍,
- កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែកឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត,
- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍,
- សហគ្រាសដែលស្ថិតក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម និង សហ-គ្រាសដែលអភិវឌ្ឍតំបន់នេះ ។

៣. សហគ្រាសធុនតូច និងមធ្យម នៃវិស័យអាទិភាពខាងលើដែលមានលទ្ធភាពបង្កើតឱកាសការងារថ្មី ចាប់ពី ៥ ឡើងទៅ ត្រូវបានលើកទឹកចិត្ត ។

លក្ខខណ្ឌនៃឥណទានក្រោមគម្រោងសហហិរញ្ញប្បទាននេះ មានដូចតទៅ÷

| **បរិយាយ** | **លក្ខខណ្ឌ** |
|---|---|
| គោលបំណងនៃការប្រើប្រាស់ និងទំហំ ឥណទាន | ឥណទានសម្រាប់ប្រើជាទុនបង្វិល មានទំហំអតិបរិមា ២០០ ០០០ (ម្ភៃម៉ឺន) ដុល្លារអាមេរិក និង/ឬ ឥណទានសម្រាប់ប្រើជាចំណាយមូលធន មានទំហំអតិបរមា ៣០០ ០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក (ហិរញ្ញប្បទានសរុប អតិបរមា ៣០០ ០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក) |

| | |
|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | អតិបរមា ៧ ភាគរយ |
| រយៈពេលនៃឥណទាន | មិនលើសពី ៤ ឆ្នាំ |
| លក្ខខណ្ឌផ្សេងទៀត | អាស្រ័យលើលក្ខខណ្ឌឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមនីមួយៗ |

ហេតុដូច្នេះ ម្ចាស់សហគ្រាសធុនតូច និងមធ្យមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមលក្ខខណ្ឌតម្រូវ ដូចបានជម្រាបជូនខាងលើ អាចដាក់ពាក្យស្នើសុំឥណទានក្រោមគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដោយធ្វើទំនាក់ទំនងផ្ទាល់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមណាមួយ ដូចមានរាយឈ្មោះក្នុងបញ្ជីភ្ជាប់ជាមួយ ។

សម្រាប់ការសាកសួរព័ត៌មានបន្ថែម ឬមានចម្ងល់ផ្សេងៗ សូមទាក់ទងបុគ្គលិករបស់ធនាគារសហគ្រាស ធុនតូច និងមធ្យមកម្ពុជា (ធ.ស.ក) ដូចខាងក្រោម÷

១. លោក **សួន សុភា**, ទូរស័ព្ទលេខ 099 34 7777, អ៊ីម៉េល sophea.suon7@gmail.com

២. លោក **អេង តុងងី**, ទូរស័ព្ទលេខ 012 798 976, អ៊ីម៉េល tong_ngy@yahoo.com